ជូនចំពោះលោកអ្នកដែលបានឆ្លងមេរោគកូរ៉ូណាប្រភេទថ្មីនៅកន្លែងធ្វើការ

# ក្នុងករណីបានឆ្លងដោយសារភារកិច្ចការងារ នោះជាគោលដៅទទួលបានធានារ៉ាប់រងគ្រោះថ្នាក់ការងារ

## ករណីណាជាគោលដៅ?

■ ក្នុងករណីដែលគេអាចដឹងច្បាស់ថាផ្លូវឆ្លងរាលដាលគឺតាមរយៈភារកិច្ចការងារ

■ ទោះជាក្នុងករណីដែលគេមិនអាចដឹងច្បាស់អំពីផ្លូវឆ្លងរាលដាលក៏ដោយ ក្នុងករណីមានភារកិច្ចការងារ ដែលមានហានិភ័យឆ្លងខ្ពស់* ហើយមានភាគរយដែលបានឆ្លងតាមរយៈការងារនោះខ្ពស់

*(ឧទាហរណ៍១) ភារកិច្ចការងារនៅកន្លែង ដែលគេបានរកឃើញអ្នកឆ្លងច្រើននាក់

*(ឧទាហរណ៍២) ភារកិច្ចការងារដែលតម្រូវអោយនៅក្បែរ ឬប៉ះពាល់ជាមួយអតិថិជនញឹកញាប់។ល។

■ ចំពោះលោកអ្នកដែលមានភារកិច្ចការងារជាគ្រូពេទ្យ គិលានុបដ្ឋាយិកា និងអ្នកមើលថែទាំ ជាគោលការណ៍ គឺជាគោលដៅ លើកលែងតែក្នុងករណីដែលគេអាចដឹងច្បាស់ថាបានឆ្លងតាមរយៈផ្លូវផ្សេងក្រៅពីការងារ

## ប្រភេទធានារ៉ាប់រងគ្រោះថ្នាក់ការងារ

កម្មករនិយោជិតដែលបានឆ្លងមេរោគកូរ៉ូណាប្រភេទថ្មីដោយសារភារកិច្ចការងារ និងគ្រួសាររបស់គេ ទោះបីជាប្រភេទនៃកិច្ចសន្យាការងារណាមួយក៏ដោយ ដូចជាបុគ្គលិកពេញម៉ោង អ្នកធ្វើការមិនពេញម៉ោង អ្នកធ្វើការក្រៅម៉ោងជាដើម អាចទទួលបានប្រាក់ឧបត្ថម្ភសំណងខាងក្រោមបាន៖

### ប្រាក់ឧបត្ថម្ភសំណងព្យាបាល

①ក្នុងករណីទៅព្យាបាលនៅស្ថាប័នវេជ្ជសាស្ត្រកំណត់សម្រាប់គ្រោះថ្នាក់ការងារ ជាគោលការណ៍អាចទទួលបានការព្យាបាលដោយឥតគិតថ្លៃ។

②ក្នុងករណីគ្មានជម្រើសត្រូវទទួលការព្យាបាលនៅកន្លែងផ្សេងក្រៅពីស្ថាប័នវេជ្ជសាស្ត្រកំណត់សម្រាប់គ្រោះថ្នាក់ការងារ ត្រូវចេញថ្លៃព្យាបាលសិន ហើយក្រោយមកតាមរយៈការស្នើរសុំ ថ្លៃចំណាយដែលបានចេញ នឹងត្រូវបានសងវិញគ្រប់ចំនួន។

### ប្រាក់ឧបត្ថម្ភសំណងឈប់សម្រាក

ក្នុងករណីត្រូវឈប់សម្រាកការងារដើម្បីព្យាបាល ហើយមិនទទួលបានប្រាក់ឈ្នួល អាចទទួលបានប្រាក់ឧបត្ថម្ភសំណង។

■ ថ្ងៃឧបត្ថម្ភ៖ ចាប់ពីថ្ងៃទី4នៃការឈប់សម្រាក

■ ទឹកប្រាក់ឧបត្ថម្ភ៖ 80%នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ(រួមទាំងប្រាក់ឧបត្ថម្ភពិសេស20%ផង) សម្រាប់ការឈប់សម្រាក១ថ្ងៃ

*ជាទូទៅ "ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ" ត្រូវបានគណនាដោយយកប្រាក់ឈ្នួលរយៈពេល3ខែមុនថ្ងៃឈឺ ចែកនឹងចំនួនថ្ងៃ

### ប្រាក់ឧបត្ថម្ភសំណងគ្រួសារ

គ្រួសារនៃកម្មករនិយោជិតដែលបានស្លាប់ដោយសារការឆ្លងតាមរយៈភារកិច្ចការងារ អាចទទួលបានប្រាក់សោធនសំណងគ្រួសារ ប្រាក់សំណងគ្រួសារបើកផ្តាច់។ល។

■ សំរាប់ការសាកសួរ សូមទាក់ទងទៅនាយកដ្ឋានការងារ ឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅក្បែរកន្លែងអ្នក ▶

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព នាយកដ្ឋានការងារតាមខេត្តក្រុង ការិយាល័យត្រួតពិនិត្យស្តង់ដារការងារ

(2020.11)